# ការសង្គ្រោះបន្ទាន់នៅក្នុងគ្លីនិកធ្មេញ

នៅពេលការព្យាបាលធ្មេញត្រូវបានរៀបចំធ្វើឡើង យ៉ាងហោចគួរមានមនុស្សចំនួន២នាក់ដើម្បីដោះស្រាយនឹងការសង្គ្រោះបន្ទាន់នានា។ គ្រប់សមាជិកនៃបុគ្គលិកទាំងអស់ ត្រូវដឹងពីមុខនាទីរបស់ពួកគេ ក្នុងករណីអ្នកជំងឺដួលសន្លប់ រឺ មានការសង្គ្រោះបន្ទាន់កើតឡើង។ គ្រប់សមាជិកនៃបុគ្គលិកទាំងអស់ ត្រូវតែបានទទួលការបណ្តុះបណ្តាល និងរៀបចំខ្លួនរួចជាស្រេចសំរាប់ការសង្គ្រោះបន្ទាន់នានា។ ក្រុមគ្រូពេទ្យទន្តសាស្រ្ត គួរធ្វើការអនុវត្តជាប្រចាំនូវការសង្គ្រោះបន្ទាន់សាកល្បង ដូចនេះពួកគេដឹងយ៉ាងប្រាកដថាអ្វីដែលត្រូវធ្វើ។

វាគឺសំខាន់ក្នុងការព្យាយាម និង ដឹងនៅពេលដែលអ្នកជំងឺមិនស្រួល ដូច្នោះវិធានការដំបូងអាចធ្វើទៅបាន, ជំនួយអាចស្វែងរកបាន, ហើយសំភារៈ រឺ ថ្នាំត្រូវរៀបចំជាស្រេចសំរាប់ប្រើប្រាស់។

**អ្នក**ត្រូវតែត្រៀមខ្លួនរួចជាស្រេចដើម្បីធ្វើជាអ្នកជួយសង្គ្រោះដំបូង និង ធ្វើការសំរេចចិត្តអំពីអ្វីដែលកើតឡើងខុសប្រក្រតី ហើយមានលទ្ធភាពចាប់ផ្តើមព្យាបាលអ្នកជំងឺរហូតដល់ជំនួយមកដល់។

មុននឹងធ្វើការវាយតំលៃអ្នកជំងឺ វាសំខាន់បំផុតដែលអ្នកត្រូវធ្វើការវាយតំលៃបរិស្ថានជុំវិញដើម្បីធានាអោយច្បាស់ថាវាមានសុវត្ថិភាពក្នុងការដំណើរការនោះ។

ប្រសិនបើអ្នកជំងឺនៅមានស្មារតី អ្នកត្រូវសួរអ្នកជំងឺថា "តើអ្នកសុខសប្បាយទេរឺ?" ប្រសិនបើ អ្នកជំងឺឆ្លើយតបជាធម្មតា នោះពួកគេនឹងកំពុងដកដង្ហើម ហើយខួរក្បាលរបស់គេក៏កំពុងតែទទួលអ៊ុកស៊ីសែនដែរ។

ប្រសិនបើអ្នកជំងឺបាត់ស្មារតី ត្រូវអង្រួនពួកគេថ្នមៗ ហើយសួរថា " តើអ្នកអត់អីទេរឺ?" ។ ប្រសិនបើគ្មានការឆ្លើយតប--ស្រែករកជំនួយ



ត្រូវធានាអោយច្បាស់ថាផ្លូវដង្ហើមបើក--**ផ្ងៀងក្បាលទៅក្រោយ--លើកចង្ការឡើង**-- ត្រូវត្រួតពិនិត្យអោយលឿនថាគ្មានវត្ថុអ្វីមួយ ឈាម រឺ ស្លេស នៅស្ទះក្នុងមាត់--ត្រូវសំអាតវាយកចេញដោយម្រាមដៃ រឺ បំពង់បឺតទឹកមាត់ ប្រសិនបើចាំបាច់។

ការដកដង្ហើម? **មើល - ទទួលអារម្មណ៍ - ស្តាប់**

ដាក់ត្រចៀកជិតមាត់អ្នកជំងឺ ដូចនេះអ្នកអាចលឺថាតើមានដង្ហើមរឺទេ។

ដោយដាក់មុខរបស់អ្នក នៅជិតមាត់អ្នកជំងឺ អ្នកនឹងទទួលអារម្មណ៍ថាមានដង្ហើមរឺទេ។

អ្នកអាចមើលតាមបណ្តោយទ្រូងរបស់អ្នកជំងឺ ហើយមើលពីចលនាណាមួយរបស់ទ្រូងនោះ។

ធ្វើដូចនេះរយៈពេល១០នាទី។



ចាប់ផ្តើមធ្វើការសង្កត់ទ្រូងក្នុងអត្រា ១០០ដងក្នុង១នាទី។ រាប់អោយបានលឺៗ នៅពេលអ្នកសង្កត់ទ្រូងបាន ៣០ដង។ រួចមកផ្លុះខ្យល់សង្គ្រោះ២ដង រួចសង្កត់ទ្រូង ៣០ដងទៀត ហើយបន្តធ្វើរហូតដល់ចរន្តឈាមត្រលប់មកវិញ។

ត្រូវចាំថាខ្យល់មានអុកស៊ីសែនតែ២០%ប៉ុណ្ណោះ ហើយខ្យល់ដែលអ្នកដកដង្ហើមចេញនឹងមានអុកស៊ីសែនតែ ១៤% ប៉ុណ្ណោះ។ ប្រសិនបើអាចផ្តល់អុកស៊ីសែន រឺ ប្រើស្បោងច្របាច់ខ្យល់វិញ។

ប្រសិនបើមានមនុស្សពីរនាក់ ម្នាក់ធ្វើការសង្កត់ទ្រូង ហើយម្នាក់ទៀតត្រូវរក្សាផ្លូវដង្ហើមអោយបើក។

វាសំខាន់ណាស់ក្នុងការសង្កត់ទ្រូងអោយត្រូវចង្វាក់ល្អ ដោយសារការសង្កត់នេះតែម្យ៉ាងក៏ធ្វើអោយខ្យល់ចេញចូលសួតបានតិចតួចដែរ។

**ការសន្លប់** គឺជាមូលហេតុចំបងនៃការបាត់បង់ស្មារតីរបស់អ្នកជំងឺនៅក្នុងគ្លីនិក។ វាបណ្តាលមកពីខ្វះឈាមទៅកាន់ខួរក្បាល។

វាអាចបណ្តាលមកពីការភ័យខ្លាច ការឃ្លានរហិតរហៃ ក្តៅខ្លាំងពេក រឺ បន្ទាប់ពីទទួលចាក់ថ្នាំស្ពឹកដែលមានadrenaline/epinephrine។

នៅពេលអ្នកជំងឺបានទទួលចាក់ថ្នាំស្ពឹកហើយ ត្រូវឃ្លាំងមើលអ្នកជំងឺបីបួននាទីដើម្បីបញ្ជាក់អោយច្បាស់ថា មិនបានចាក់ចូលទៅក្នុងសរសៃឈាម។ ប្រសិនបើអ្នកជំងឺដេកសណ្តូកត្រង់ (supine) នៅលើកៅអីធ្មេញ នោះការសន្លប់មិនទំនងជាកើតមានច្រើនទេ។ ជារឿយៗសញ្ញាណដំបូង ដែលអ្នកជំងឺអាចនឹងសន្លប់នោះគឺការផ្លាស់ប្តូរពណ៌សំបុររបស់គេ។ ស្បែករបស់គេនឹងស្លេក។ អ្នកជំងឺនឹងដឹងខ្លួនថាគេមិនសូវមានអារម្មណ៍ល្អ-ពួកគេអាចនិយាយថាពួកគេដូចជាមិនសូវស្រួល។ កុំដាក់កៅអីបញ្ឈរឡើងត្រង់--ប៉ុន្តែ ដាក់វាដេកទាបត្រង់តាមដែលអាចធ្វើទៅបានដោយអោយជើងខ្ពស់ជាងក្បាល (ការធ្វើដូចនេះជួយអោយលំហូរឈាមទៅខួរក្បាលកើនឡើង)។ ជួយសំរួលអារម្មណ៍អ្នកជំងឺប្រសិនបើអាច--និយាយទៅកាន់ពួកគេ និង លើកទឹកចិត្តពួកគេ។ ប្រសិនបើ អ្នកជំងឺហាក់ដូចជាបាត់ស្មារតី នោះវាប្រហែលតែប៉ុន្មានវិនាទីប៉ុណ្ណោះ--ជួនកាលមានការតឹងសាច់ដុំ និង ចលនាមិនគ្រប់គ្រាន់។

បន្ទាប់ពីដកធ្មេញនិងចំពោះមនុស្សចាស់ដែលបានដេកទាបត្រង់អស់មួយរយៈ ត្រូវដាក់កៅអីឈរត្រង់ និង ដាក់អោយអ្នកជំងឺអង្គុយនៅក្នុងជំហរនោះបីបួននាទីសិន មុននឹងអោយពួកគេចុះចេញពីកៅអី។ នេះជួយអោយសំពាធឈាមរបស់គេអាចសំរបសំរួលនឹងការឈរ ហើយមានឈាមគ្រប់គ្រាន់ទៅដល់ខួរក្បាល។

អ្នកជំងឺមួយចំនួនដែលមានអារម្មណ៍ខ្វល់ខ្វាយមួរមៅ រឺ ឆ្វេឆ្វាខ្លាំង ត្រូវចាំឃ្លាំងមើលចំនួន១០នាទីសិន បន្ទាប់ពីចុះចេញពីកៅអីធ្មេញដោយសារខ្លួនប្រាណរបស់គេបានផលិត adrenaline ដ៏ច្រើន ដែលនៅពេលពួកគេក្រោកឈរឡើង ហើយដើរ ពួកគេអាចនឹងដួលសន្លប់។ (ជានិច្ចកាល ត្រូវមើលអ្នកជំងឺដែលចង់ទៅបន្ទប់ទឹកភ្លាមៗក្រោយពីដកធ្មេញ--ពួកគេចង់ទៅ អាចដោយសារពួកគេមានអារម្មណ៍មិនស្រួល ហើយ អាចដួលសន្លប់នៅក្នុងបន្ទប់ទឹកដែលចាក់សោរជាប់នោះ)។

ប្រសិនបើ អ្នកជំងឺសន្លប់នៅបន្ទប់រងចាំ រឺ នៅមុខរានហាល--ដាក់អោយគេដេកសណ្តូក--ចូរដាក់អោយគេដេកក្នុង recovery position ហើយត្រូវធានាអោយច្បាស់ថាផ្លូវដង្ហើមរបស់គេចំហរ (ចង្កោរងើយឡើង) បន្ធូរសំលៀកបំពាក់ដែលតឹងនៅជុំវិញក ពិនិត្យមើលជីពចររបស់គេ ហើយប្រសិនបើ អ្នកជំងឺមិនជាស្បះស្បើយក្នុងអំឡុងពេលពីរបីនាទីទេ ត្រូវរកជំនួយ និងត្រូវពិនិត្យសញ្ញានៃភាពដឹងខ្លួនណាដែលនៅមាន ហើយវាយតំលៃស្ថានភាពនោះឡើងវិញ។

**ជំងឺឆ្កួតជ្រូក រឺ ប្រកាច់** បណ្តាលមកពីការផ្លាស់ប្តូរនៅក្នុងសកម្មភាពដំណើរការធម្មតារបស់ខួរក្បាល។ អ្នកជំងឺអាចមានការប្រកាច់ រឺ ស្មារតីចុះខ្សោយដោយមិនមានការរងគ្រោះពីជំងឺឆ្កួតជ្រូកទេ។

អ្នកជំងឺអាចអោយសញ្ញាប្រាប់អោយដឹងមុនបន្តិច ស្រែកបន្តិច ហើយ ស្មារតីចុះខ្សោយ (ដួលទៅលើដីប្រសិនបើកំពុងឈរ) ឡើងរឹងឆ្អឹងខ្នងខាងក្រោយ ដង្ហើមអាចឈប់ដក(បបូរមាត់ឡើងខៀវ) អាចខាំថ្គាមជាប់ ការដកដង្ហើមអាចលឺសូរ អាចបាត់បង់ការគ្រប់គ្រងរបស់ប្លោកនោមនិងពោះវៀន អាចមានការកន្ត្រាក់ម្រាមដៃម្រាមជើងនិងក្បាល

ការប្រកាច់អាចមានបន្តមកទៀតក្រោយការដេកលង់លក់។

អំឡុងពេលប្រកាច់យករបស់របរគ្រោះថ្នាក់ចេញអោយអស់ពីកន្លែងនោះ កត់ត្រាពេលវេលាដែលអ្នកជំងឺចាប់ផ្តើមប្រកាច់ ទ្រ និងការពារក្បាលរបស់អ្នកជំងឺ រកជំនួយបើត្រូវការ អោយមនុស្សម្នាចេញអោយឆ្ងាយ ដាក់អ្នកជំងឺដេកក្នុងជំហរ recovery position នៅពេលការប្រកាច់នោះឈប់។

ហៅឡានសង្គ្រោះបន្ទាន់ បើការប្រកាច់នោះមិនឈប់ក្នុងអំឡុងពេល៥នាទី មានការប្រកាច់លើកទីពីរកើតឡើងភ្លាម១បន្ទាប់ពីប្រកាច់រួច រឺ អ្នកជំងឺបាត់បង់ស្មារតីលើសពីរយៈពេល១០នាទី។

**ជំងឺទឹកនោមផ្អែម** ជាជំងឺដែលកើតឡើងនៅពេលខ្លួនប្រាណរបស់យើងមិនផលិត insulin គ្រប់គ្រាន់។ (Insulin គ្រប់គ្រងចំនួនជាតិស្ករក្នុងឈាម--កោសិកាទាំងអស់ត្រូវការជាតិស្ករដើម្បីរស់)។

មនុស្សមួយចំនួនត្រូវតែគ្រប់គ្រងកំរិតជាតិស្ករនៅក្នុងឈាមរបស់គេដោយការចាក់ insulin ដោយលេបថ្នាំ រឺ ដោយគ្រប់គ្រងរបបអាហាររបស់ពួកគេ និងត្រួតពិនិត្យមើលថាតើគេបរិភោគជាតិស្ករអស់ប៉ុន្មាន។

ប្រសិនបើកំរិតជាតិស្ករក្នុងឈាមធ្លាក់ចុះក្រោមកំរិតធម្មតា ខួរក្បាលនឹងមានការប៉ះពាល់យ៉ាងលឿន។ Hypoglycemia (កង្វះជាតិស្ករក្នុងឈាម) បណ្តាលមកពី insulin ច្រើនពេក បរិភោគអាហារតិចរឺភ្លេចញ៉ាំអាហារ ការធ្វើលំហាត់ប្រាណដែលមិនបានគ្រោងទុក ពិសារស្រាច្រើនពេក។

រោគសញ្ញាអាចកើតឡើងយ៉ាងរហ័ស ហើយប្រសិនបើមិនចាត់វិធានការលើកកំរិតជាតិស្ករក្នុងឈាម អ្នកជំងឺអាចបាត់បង់ស្មារតី។ ញាក់ និង ញ័រ បែកញើស ឈឺក្បាល ក្អែងក្អាងរឺច្របូកច្របល់ និយាយត្រដិតមិនច្បាស់

នៅពេលដែលអ្នកជំងឺនៅមានស្មារតីនិងសហការណ៍ អោយញ៉ាំស្ករ រឺ ទឹកស្ករ ស្ករជាគ្រាប់ រឺ ចាហួយ។ ស្ករអាចអោយម្តងទៀតបន្ទាប់ពី ១០ ទៅ ១៥នាទី បើចាំបាច់។

ប្រសិនបើ អ្នកជំងឺមិនអាចមានលទ្ធភាពសហការណ៍បានទេ នោះត្រូវចាក់ Glucagon 1mg តាមសាច់ដុំ។

**Anaphylactic shock** គឺជាស្ថានភាពដ៏ធ្ងន់ធ្ងរមួយដែលបណ្តាលមកពីប្រតិកម្ម (allergy) ទៅនឹងសំភារៈមួយចំនួន។ វាអាចជាថ្នាំដូចជា ពពួកថ្នាំសំលាប់មេរោគ ថ្នាំស្ពឹក វ៉ាក់សាំង; ម្ហូបអាហារដូចជា សណ្តែកដី ត្រីសមុទ្រ; សត្វល្អិតខាំ រឺប្រតិកម្មនឹងជ័រ រឺ សំភារៈផ្សេង១។ រោគសញ្ញារបស់ **anaphylaxis** មាន: រមាស់និងមានអារម្មណ៍ចាក់១ជុំវិញផ្ទៃមុខ ហើមបំពង់កនិងពិបាកក្នុងការដកដង្ហើម ដកដង្ហើមថបមានសំលេង ចុកពោះ ក្អួត បាត់បង់ស្មារតី។

**ហៅឡានសង្គ្រោះបន្ទាន់ភ្លាម** ផ្តល់អុកស៊ីសែន ចាក់ adrenaline តាមសាច់ដុំចំនួន 0,៥ ml នៃ ១/១000 adrenaline—អាចចាក់ adrenaline 0,៥mlទៀត ប្រសិនបើគ្មានភាពប្រសើរឡើង។ ត្រូវរៀបចំខ្លួនជានិច្ចក្នុងការធ្វើ basic life support។

**Angina** គឺជាការចុកភ្លាម១ដ៏ខ្លាំងក្នុងដើមទ្រូង ដោយសារសាច់ដុំបេះដូងមិនមានឈាមទៅចិញ្ចឹមគ្រប់គ្រាន់។ ជាទូទៅ នេះជាអ្វីដែលអ្នកជំងឺធ្លាប់មានពីមុនមក ហើយអាចមានថ្នាំពីគ្រូពេទ្យសំរាប់ការចុកនេះ។ ជាធម្មតា ការឈឺចាប់នេះកើនឡើងនៅពេលមានលំហាត់ប្រាណ រឺ ភាពតប់ប្រមល់។

រោគសញ្ញារបស់ **Angina** គឺ ការឈឺចាប់ដោយចុកទ្រូងធ្ងន់ធ្ងរ ដែលជារឿយ១រាលដាលដល់ដៃឆ្វេងនិងឆ្អឹងថ្គាម ដង្ហើមខ្លី១ ទន់ខ្សោយ។ ជួយសំរួលអោយអ្នកជំងឺអង្គុយអោយមានផាសុខភាព អោយ GTN (Glycerly Tri-Nitrate) ជាប្រភេទគ្រាប់ រឺ ទឹកបាញ់ និយាយលើកទឹកចិត្តអ្នកជំងឺ ហៅឡានសង្គ្រោះបន្ទាន់ប្រសិនបើការឈឺចាប់និងភាពមិនសុខស្រួលនៅបន្ត ក្រោយ១០នាទីនៃការផឹកថ្នាំ និងសំរាក់មក ដោយសារវាអាចជា heart attack។

**Heart Attack (Coronary or Myocardial infaction)** កើតឡើង នៅពេលឈាមទៅចិញ្ចឹមបេះដូងស្រាប់តែបញ្ឈប់ភ្លាមៗ ជាធម្មតាដោយសារកំណកឈាម រឺ កំណកខ្លាញ់នៅស្ទះសរសៃឈាម និងការខូចខាតការបញ្ចេញនៃសាច់ដុំបេះដូង--ជាធម្មតា វាមិនទាក់ទងនឹងការធ្វើលំហាត់ប្រាណខ្លាំងទេ។

រោគសញ្ញានៃជំងឺនេះមាន: ការកើនឡើងនៃការចុកនៅកណ្តាលទ្រូងរួចឆ្លងទៅខាងមុខទ្រូង ការឈឺចាប់នោះអាចរាលដាលដល់ស្មាខាងក្រោមដៃ និងចូលទៅក្នុងឆ្អឹងថ្គាម ស្បែកប្រែទៅជាស្លេកនិងសើមស្អិត ចង្អោរហើយក្អួតកើតឡើងជាញឹកញាប់ ដង្ហើមខ្លីៗ ការឈឺចាប់នោះមិនបន្ថយដោយការសំរាកទេ។
ទូរសព្ទ័ហៅឡានសង្គ្រោះបន្ទាន់ជាបន្ទាន់ អោយ GTN (Glycerly Tri- Nitrate) អោយ aspirin 300mg ដោយកិនរឺទំពារ ផ្តល់អុកស៊ីសែន (២៥ភាគរយនៃអ្នកជំងឺដែលមាន heart attack នឹងវិវត្តទៅជាគាំងបេះដូងទាំងស្រុង) ត្រៀមធ្វើ basic life support។

**ជំងឺហឺត** គឺជាបញ្ហាមួយដែលបណ្តាលអោយអ្នកជំងឺមានការពិបាកក្នុងការដកដង្ហើម។ ជាធម្មតា វាបណ្តាលមកពី irritants នៅក្នុងខ្យល់ ខ្យល់ត្រជាក់ ក្តៅ និងសើម ការធ្វើលំហាត់ប្រាណ និង ភាពតានតឹង។
រោគសញ្ញានៃជំងឺហឺតមាន ពិបាកក្នុងការនិយាយ ដង្ហើមខ្លីៗញាប់ៗ ចង្វាក់បេះដូងកើនឡើង អ្នកជំងឺប្រើសាច់ដុំកទាំងអស់ដើម្បីព្យាយាមដកដង្ហើម អស់កំលាំងនិងវង្វេងវង្វាន់។
ដាក់អោយអ្នកជំងឺអង្គុយអោយស្រួល ហើយនិយាយលើកទឹកចិត្តគេ បន្ធូរសំលៀកបំពាក់តឹងៗ អោយអ្នកជំងឺប្រើម៉ាស៊ីនដកដង្ហើមដើម្បីស្រូបថ្នាំរបស់គេ (ជាធម្មតាពណ៌ខៀវសំរាប់ថ្នាំ salbutamol) ប្រសិនបើអ្នកជំងឺមិនធូរស្បើយលឿន រឺ មានសញ្ញានៃការហឺតធ្ងន់ធ្ងរ ត្រូវហៅឡានសង្គ្រោះបន្ទាន់។